## តើអ្នកអាចជួយបានយ៉ាងម៉េច?



ចូរនិយាយជាមួយមិត្តភក្តិ និងគ្រួសារណាដែលអាចមានការលំបាកក្នុងការចំណាយលើម្ហូបអាហារ។ ប្រាប់ឲ្យពួកគេដឹងពីជំនួយម្ហូបអាហារនេះ។

**សូមទូរសព្ទទៅលេខទាន់ហេតុការណ៍តាមមូលដ្ឋាន SNAP**

**1-866-306-0270 ដើម្បីទទួលបានព័ត៌មាន និងជំនួយ។**

បុគ្គលិកតាមមូលដ្ឋានដែលបានហាត់រៀន អាចឆ្លើយសំណួររបស់អ្នក ពន្យល់ពីដំណើរការដាក់ពាក្យសុំ SNAP និងផ្តល់ជូនអ្នកនូវទីតាំង និងលេខទូរសព្ទរបស់ការិយាល័យ DHS ដែលនៅជិតបំផុត ដែលនឹងធ្វើការលើពាក្យសុំ SNAP ។

**ជាផ្នែកមួយនៃដំណើរការផ្ទៀងផ្ទាត់របស់ SNAP មនុស្សភាគច្រើននឹងត្រូវផ្តល់៖**

- អត្តសញ្ញាណ (ដូចជាបណ្ណបើកបរ ឬ សំបុត្រកំណើត)
- លេខសន្តិសុខសង្គមរបស់អ្នករាល់គ្នានៅក្នុងគ្រួសារដែលដាក់ពាក្យសុំអត្ថប្រយោជន៍ (រួមទាំងកុមារ)
- តឹកតាងបញ្ជាក់ប្រាក់ចំណូល (ដូចជាបង្កាន់ដៃបើកប្រាក់ជាដើម)

### ក៏មានធនធានលើបណ្តាញដែលអ្នកអាចប្រើប្រាស់បានផងដែរ៖

ដើម្បីស្វែងយល់បន្ថែមអំពី SNAP៖ www.eatbettertoday.com

ដើម្បីដាក់ពាក្យសុំ SNAP៖ www.dhs.ri.gov

គម្រោងតាមមូលដ្ឋាន SNAP គឺជាកិច្ចសហការមួយរវាងមជ្ឈមណ្ឌល URI Feinstein សម្រាប់បំបាត់ភាពអត់ឃ្លាននៅអាមេរិក នាយកដ្ឋានសេវាកម្មមនុស្សរបស់ RI និងក្រសួងកសិកម្មសហរដ្ឋអាមេរិក។ សកលវិទ្យាល័យ Rhode Island គឺជានិយោជកផ្តល់ឱកាសស្មើគ្នាដែលប្តេជ្ញាគោរពតាមគោលការណ៍ចំណាត់ការវិជ្ជមាន។ USDA គឺជានិយោជិក អ្នកឲ្យខ្ចី និងអ្នកផ្តល់ឱកាសស្មើគ្នា ខែតុលា '18

# តើអ្នកស្គាល់នរណាម្នាក់ដែលអាចប្រើជំនួយតិចតួចក្នុងការទិញម្ហូបអាហារឬទេ?



## មានវិធីមួយដែលអ្នកអាចជួយបាន។

គម្រោងតាមមូលដ្ឋាន **URI SNAP**

**1-866-306-0270**

www.eatbettertoday.com

# វាជាការសំខាន់ក្នុងការមើលថែគ្នាទៅវិញទៅមក។



វាអាចធ្វើឲ្យពិបាកចិត្តនៅពេលឃើញមិត្តណាម្នាក់កំពុងតែខ្វះខាត។

នោះហើយជាមូលហេតុដែលយើងចង់ឲ្យអ្នកដឹងពី **កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម** ឬហៅកាត់ថា **SNAP** ។

នៅពេលមនុស្សកំពុងឆ្លងកាត់ពេលវេលាលំបាកលំបិន អត្ថប្រយោជន៍ SNAP អាចជួយពួកគេទិញម្ហូបអាហារដែលពួកគេត្រូវការបាន ដើម្បីរក្សាសុខភាពឲ្យបានល្អ។ នៅពេលនរណាម្នាក់ប្រើកាត SNAP EBT របស់ពួកគេដើម្បីទិញម្ហូបអាហារ ពួកគេមិនត្រឹមតែកំពុងជួយខ្លួនឯងនោះទេ ប៉ុន្តែថែមទាំងកំពុងជួយជ្រោមជ្រែងសេដ្ឋកិច្ចមូលដ្ឋានទៀតផង។

**ការពិតអំពី SNAP**

- អ្នកចូលរួមជាមួយ SNAP អាចមានផ្ទះ ឡាន និងគណនីធនាគារ។
- អ្នកចូលរួមជាមួយ SNAP ជាច្រើន មានការងារធ្វើ។ អ្នកចូលរួមជាមួយ SNAP អាចធ្វើការ និងនៅតែទទួលបានអត្ថប្រយោជន៍ ដូចនេះការងារមិនមែនជាតម្រូវការដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍នោះទេ។
- SNAP ត្រូវបានផ្តល់មូលនិធិដោយសហព័ន្ធ។ មានអត្ថប្រយោជន៍គ្រប់គ្រាន់សម្រាប់អ្នករាល់គ្នាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- អ្នកចូលរួមជាមួយ SNAP អាចនឹងមានសិទ្ធិទទួលបានថ្លៃសេវាទូរសព្ទ និងអគ្គិសនីទាបជាង។
- ក្មេងៗក្នុងគ្រួសារដែលទទួលបាន SNAP មានសិទ្ធិទទួលបានអាហារនៅសាលារៀនដោយឥតគិតថ្លៃ។

**គម្រោងតាមមូលដ្ឋាន SNAP នៅទីនេះដើម្បីផ្តល់ជំនួយ។**

**សូមទូរសព្ទមកយើងដោយឥតគិតថ្លៃទៅលេខ 1-866-306-0270**

# មនុស្សជាច្រើនភ្ញាក់ផ្អើលនៅពេលដឹងថា ពួកគេមានសិទ្ធិទទួលបានអត្ថប្រយោជន៍

បុគ្គល ឬ គ្រួសារ ដែលមានចំណូលប្រចាំខែ ស្មើ ឬ ក្រោម កម្រិតក្នុងតារាងខាងក្រោម អាចនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ SNAP ។

| ទំហំគ្រួសារ | ចំណូលសរុបប្រចាំខែអតិបរមា* |
|---|---|
| 1 | $1,872 |
| 2 | $2,538 |
| 3 | $3,204 |
| 4 | $3,870 |
| 5 | $4,536 |
| 6 | $5,202 |
| 7 | $5,868 |
| ច្រើននាក់ទៀត | +$666 |

*កម្រិតចំណូលទាំងនេះអនុវត្តចាប់ពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2018 ដល់ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2019

ការមានចំណូលត្រូវតាមកម្រិតណែនាំខាងលើនេះ គឺជាជំហានដំបូងទៅកាន់ភាពមានសិទ្ធិទទួលបាន SNAP ។

ជំហានទីពីរដើម្បីមានសិទ្ធិទទួល គឺត្រូវបានកំណត់ដោយនាយកដ្ឋានសេវាកម្មមនុស្ស (DHS) នៃកោះ Rhode Island ដែលជាភ្នាក់ងារនៅក្នុងរដ្ឋដែលគ្រប់គ្រង SNAP ។ជំហានទីពីរដើម្បីមានសិទ្ធិទទួល គឺត្រូវបានកំណត់ដោយនាយកដ្ឋានសេវាកម្មមនុស្ស (DHS) នៃកោះ Rhode Island ដែលជាភ្នាក់ងារនៅក្នុងរដ្ឋដែលគ្រប់គ្រង SNAP ។

DHS នឹងកាត់កងការចំណាយមួយចំនួនដោយដកពីចំណូលសរុបដើម្បីពិនិត្យមើលថាតើការសាកល្បងចំណូលពិត ត្រូវតាមកម្រិតដែរឬទេ។

បើនរណាម្នាក់ក្នុងគ្រួសារ គឺជាចាស់ជរា ឬមនុស្សពិការ រីឯប្រាក់ចំណូលប្រចាំខែខ្ពស់ជាងតម្លៃនៅក្នុងតារាង គ្រួសារនោះនៅតែអាចមានសិទ្ធិទទួលបានអត្ថប្រយោជន៍ SNAP ។

**សូមទូរសព្ទមកគម្រោងតាមមូលដ្ឋាន SNAP នៅថ្ងៃនេះ**

**ដើម្បីសុំដាក់ពាក្យ ឬទទួលព័ត៌មានបន្ថែម។**

ទូរស័ព្ទមកកាន់យើងតាមរយៈលេខឥតគិតថ្លៃ៖ 1-866-306-0270